អំពីការចេញផ្សាយការចំណាយលើប្រយោជន៍សាធារណៈ

រដ្ឋបាលលោកប្រធានាធិបតី ត្រាំ កំពុងព្យាយាមផ្លាស់ប្តូរគោលការណ៍រដ្ឋាភិបាលទាក់ទងនឹងលក្ខខណ្ឌសំណើសុំនៅពេលដែល គ្លម្នាក់ដាក់ពាក្យស្នើរសុំរដ្ឋបាលមកសហរដ្ឋអាមេរិក ឬស្នើប័ណ្ណបៃតងរស់នៅអាមេរិក ឬ “ការស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់”។ លក្ខខណ្ឌទាំងនេះត្រូវបានរៀបចំឡើងដើម្បីកំណត់ថាតើបុគ្គលម្នាក់អាចក្លាយជា “បុគ្គលដែលរដ្ឋាភិបាល ត្រូវចំណាយប្រយោជន៍សាធារណៈ:ឱ្យ” ឬជាបុគ្គលដែលប្រើប្រាស់អត្ថប្រយោជន៍សាធារណៈ: នៅពេលអនាគត។

ជាពិសេស
ច្បាប់ដែលបានស្នើឡើងបានពង្រីកបញ្ជីនៃអត្ថប្រយោជន៍សហព័ន្ធដែលរដ្ឋាភិបាលអាចពិចារណាជាផ្នែកមួយនៃដំណើរការនេះ។ ការប្រើអត្ថប្រយោជន៍សហព័ន្ធបច្ចុប្បន្ន ឬអតីតរបស់បុគ្គលម្នាក់អាចរារាំងគាត់មិនឱ្យទទួលបានការអនុញ្ញាត ឬទទួលបានប័ណ្ណបៃតង។

Seattle
Office of Immigrant
and Refugee Affairs

ការបដិសេធ

FAQ នេះ ឬផ្នែក “សំណួរដែលត្រូវបានសួរជាញឹកញាប់” មានព័ត៌មានទូទៅ និងមិនមែន ជាការប្រឹក្សាស្របច្បាប់ទេ។ ប្រសិនបើអ្នកមានសំណួរអំពីស្ថានភាពជាក់ស្តែង ឬការ ប្រើប្រាស់អត្ថប្រយោជន៍របស់អ្នក អ្នកគួរតែនិយាយជាមួយមេធាវីអន្តោប្រវេសន៍ ឬអ្នកតំណាងដែលទទួលស្គាល់ដោយ DOJ។

1.
តើអ្វីជា “ការចំណាយលើប្រយោជន៍សាធារណៈ?”

រដ្ឋាភិបាលសហព័ន្ធប្រើពាក្យថា "ការចំណាយលើប្រយោជន៍សាធារណៈ" ជាស្លាកមួយតំណាងអោយជនអន្តោប្រវេសន៍ដែលពឹងផ្អែកជាចម្បងលើរដ្ឋាភិបាលដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេ។ នៅក្រោមច្បាប់ថ្មីដែលបានស្នើឡើងមក
រដ្ឋាភិបាលស្វែករកការកំណត់អត្តនិយមនៃបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈឲ្យជាបុគ្គលណាម្នាក់ដែលទទួលបានផលប្រយោជន៍សាធារណៈរបស់សហព័ន្ធមួយឬច្រើនដូចដែលមានរៀបរាប់ក្នុងច្បាប់នេះ។ (សូមមើលសំណួរទី 4 សម្រាប់ព័ត៌មានបន្ថែមនៅអត្ថប្រយោជន៍ទាំងនេះ)

2.
តើនៅពេលណាដែលរដ្ឋាភិបាលសហព័ន្ធត្រូវកំណត់ប្រសិនបើអ្នកទ់នងអាចក្លាយជាបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈឲ្យ?

រដ្ឋាភិបាលសហព័ន្ធអនុវត្តការធ្វើតេស្តចំពោះបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈឲ្យ នៅពេលដែលបុគ្គលម្នាក់ដាក់ពាក្យសុំចូលសហរដ្ឋអាមេរិក
ឬនៅពេលដែលបុគ្គលម្នាក់ស្នើសុំក្លាយជាអ្នកកាន់ប័ណ្ណបៃតង (ដែលត្រូវបានស្គាល់ថាជា "អ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់") ក្នុងចំណោមករណីផ្សេងទៀត។

នៅពេលដែលអ្នកដាក់ពាក្យសុំទិដ្ឋាការ ឬប័ណ្ណបៃតង អ្នកត្រូវតែដាក់ពាក្យសុំ។
ការប្រើប្រាស់ព័ត៌មានពីពាក្យបែបបទនិងពីការសម្ភាសន៍ដូចខាងក្រោម
រដ្ឋាភិបាលនឹងសម្រេចថាតើអ្នកទំនងអាចក្លាយជា
"បុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈ:ឲ្យ" ដែរឬទេ។

<u>គេស្គាល់លាក់នេះមិនត្រូវបានប្រើនៅពេលដែលមនុស្សម្នាក់ដែលមានប័ណ្ណបៃតងរួចហើយ ដាក់ពាក្យសុំធ្វើជាពលរដ្ឋអាមេរិក នោះទេ។</u>

3.
តើរដ្ឋាភិបាលសហព័ន្ធសម្រេចចិត្តយ៉ាងណា ប្រសិនបើអ្នកទំនងជាក្លាយជាបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈ:ឲ្យ?
នៅក្រោមច្បាប់ដែលបានស្នើឡើង
ការសម្រេចលើបបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈ:ឲ្យផ្អែកលើហេតុផលផ្សេងៗជាច្រើន។
មន្ត្រីអន្តោប្រវេសន៍ធ្វើតេស្ត "totality of circumstances (ស្ថានភាពទាំងស្រុង)"។ តេស្តនេះពិនិត្យលើអាយុ

សុខភាព ស្ថានភាពគ្រួសារ ទ្រព្យសម្បត្តិ ធនធាន ស្ថានភាពហិរញ្ញវត្ថុ ការអប់រំ និងជំនាញ។ ម្យ៉ាងវិញទៀត
រដ្ឋាភិបាលត្រូវតែពិនិត្យមើលស្ថានភាពបុគ្គលរបស់អ្នកទាំងមូលដើម្បីសម្រេចថាតើអ្នកអាចនឹងពឹងផ្អែកលើអត្ថប្រយោជន៍សាធារណៈនាពេលអនាគត ឬទេ។

លើសពីនេះទៀតនៅពេលដែលដែលលិខិតបញ្ជាក់ពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដែលត្រូវបានទាមទារដោយច្បាប់
អវត្តមាននៃភស្តុតាងបែបនេះបង្ហាញពីការដែលបុគ្គលមិនទទួលបានផលប្រយោជន៍មូលដ្ឋាននៃបន្ទុកសាធារណៈ។ លិខិតបញ្ជាក់ពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុគឺជាកិច្ចសន្យាស្របច្បាប់ដែលបុគ្គលម្នាក់ (ហៅថាសញ្ញា "sponsor (អ្នកធានា")

ចុះហត្ថលេខាដើម្បីទទួលទទួលខុសត្រូវលើទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុសម្រាប់បុគ្គលម្នាក់ទៀតដែលកំពុងមកសហរដ្ឋអាមេរិចដើម្បីរស់នៅជាអចិន្ត្រៃយ៍។

4.
នៅក្រោមសំណើថ្មី តើអ្វីជាលក្ខខណ្ឌថ្មីដែលត្រូវសម្រេចថាបុគ្គលណាជាបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈ:ឲ្យ?
នៅក្រោមច្បាប់ដែលបានស្នើឡើងដែលមិនទាន់បានសំរេចចេញ
អ្នកអាចត្រូវបានចាត់ទុកជាបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជ
ន៍សាធារណៈឱ្យប្រសិនបើអ្នកកំពុងប្រើ ឬបានប្រើកម្មវិធីណាមួយខាងក្រោម។
ការពិចារណានេះអាស្រ័យលើកត្តាជាច្រើនដូចជាពេលវេលា និងកំឡុងពេលនៃការប្រើប្រាស់
និងតម្លៃនៃអត្ថប្រយោជន៍ដែលទទួលបាន លើសពីនេះទៅទៀតកត្តាផ្សេងទៀតដែលបានរៀបរាប់
ខាងលើដូចជាសុខភាពអាយុ និងធនធានហិរញ្ញវត្ថុ។

មានតែកម្មវិធីដែលមានសញ្ញា a * តែប៉ុណ្ណោះដែលត្រូវបានពិចារណានៅក្រោមទម្រង់តេស្តបច្ចុប្បន្ននៃបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈអោយ។ច្បាប់ដែលបានស្នើឡើងនឹងបន្ថែមនៅក្នុងកម្មវិធីដែលនៅសល់។

1. កម្មវិធីជំនួយការថវិការ* រួមបញ្ចូល:
   a. Temporary Assistance for Needy Families ,TANF*
   b. Supplemental Security Income (SSI, ប្រាក់ចំណូលសន្តិសុខបន្ថែម), ដែលជួយដល់បុគ្គលដែលមានប្រាក់ចំណូលមា នកម្រិតនិងពិការភាពខ្វាក់ឬមានអាយុ 65 ឆ្នាំឬចាស់ជាងនេះ។*
   c. General Assistance (ជំនួយទូទៅ) ឬកម្មវិធីជំនួយថវិការក្នុងតំបន់ផ្សេងទៀត។*
2. ស្ថាប័នសម្រាប់ការថែទាំរយៈពេលវែង*
3. ការធានារ៉ាប់រងសុខភាព Medicaid
   លើកលែងតែលក្ខខណ្ឌសង្គ្រោះបន្ទាន់និងសេវាកម្មឬអត្ថប្រយោជន៍ដែលទទួលមូលនិធិពី Medicaid (មេឌីខេដ) ប៉ុន្តែបានផ្តល់ជូនក្រោមរូបភាពនៃ Individuals with Disabilities Education Act (IDEA,

ច្បាប់ស្តីពីការ អប់រំចំពោះគ្ពលដែលមានពិការភាព)
និងអត្ថប្រយោជន៍ដែលបានផ្តល់ដល់កុមារដែលកើតនៅក្រៅប្រទេស
ខណ:ដែលឪពុកម្តាយជាពលរដ្ឋអាមេរិក។

4. Supplemental Nutrition Assistance Program ,SNAP(កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម), ដែលពីមុនហៅថា "តែមអាហារ"។
5. Medicare Part D(មេឌីឃែ ផ្នែក D)
   ការឧបត្ថម្ភសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាបលើផ្លែផ្ការំពេទ្យតាមវេជ្ជបញ្ជា។
6. ជំនួយសហព័ន្ធលើផ្លែជួលផ្ទះដូចជា Section 8 housing vouchers(ប័ណ្ណលំនៅដ្ឋានផ្នែកទី 8) និងលំនៅដ្ឋានណាមួយដែលទទួលបានមូលនិធិដោយ Project Based Section 8(គំរោងផ្នែកលើ ផ្នែកទី 8) ។
7. លំនៅដ្ឋានដែលទទួលបានការឧបត្ថម្ភធនខ្ពស់តាមរយ:រដ្ឋាភិបាលសហព័ន្ធ។

5.
នៅក្រោមសំណើថ្មីតើកម្មវិធីអ្វីត្រូវបានដកចេញពីលក្ខខណ្ឌថ្មីដើម្បីពិចារណាថាបុគ្គលណាជាបុគ្គលដែលរដ្ឋាភិបាល ត្រូវចំណាយប្រយោជន៍សាធារណ:ឱ្យ?

ការជួយសង្គ្រោះលើគ្រោះមហន្តរាយ ជំនួយវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់; កម្មវិធីរដ្ឋ, ក្នុងស្រុកឬកុលសម្ព័ន្ធទាំងមូល (ក្រៅពីជំនួយជាសាច់ប្រាក់) អត្ថប្រយោជន៍ទទួលបានដោយសមាជិកគ្រួសាររបស់ជនអន្តោប្រវេសន៍ ឬអត្ថប្រយោជន៍ផ្សេងទៀតដែលមិនត្រូវបានបញ្ជាក់នៅក្នុងច្បាប់ដែលបានស្នើ។
អត្ថប្រយោជន៍ដែលមិនបានចុះបញ្ជីដូចជាការអប់រំ ការអភិវឌ្ឍលើកុមារ និងកម្មវិធីបណ្តុះបណ្តាលការងារ និងការងារក៏ត្រូវបានដកចេញដែរ។ រដ្ឋាភិបាលសហព័ន្ធកំពុងស្វែងរកយោ បល់ជាសាធារណ:លើ Children's Health Insurance Program (CHIP))កម្មវិធីធានារ៉ាប់រងសុខភាពកុមារ(ថាតើគួរតែត្រូវបានពិចារណាដែរឬទេ។ កម្មវិធីក្នុងតំបន់ផ្សេងៗនៅក្នុងក្រុង Utility Discount Program)
កម្មវិធីបញ្ចុះតម្លៃឧបករណ៍ប្រើប្រាស់(និងកម្មវិធី Seattle Preschool Program)
កម្មវិធីមត្តេយសិក្សាទីក្រុងស៊ីថល(នឹងមិនត្រូវបានពិចារណាទេ។

ចូលទីនេះដើម្បីមើលកម្មវិធីជាច្រើននៃទីក្រុងស៊ីថលដែលអ្នកអាចមានសិទ្ធិទទួលបានដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក: www.seattle.gov/affordable។

6.
ប្រសិនបើសមាជិកគ្រួសាររបស់ខ្ញុំប្រើប្រាស់ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ ឬកម្មវិធីផ្សេងទៀត តើយ៉ាងម៉េចវិញ?

ជាទូទៅរដ្ឋាភិបាលសហព័ន្ធនឹងពិចារណាលើអត្ថប្រយោជន៍ដែលអ្នកទទួលបានក្នុងនាមអ្នកជាអ្នកដាក់ពាក្យ ស្នើសុំតែប៉ុណ្ណោះមិនមែនសមាជិកគ្រួសាររបស់អ្នកនោះទេ។ ប្រសិនបើសំណើថ្មីនេះចូលជាធរមាន
រដ្ឋាភិបាលសហព័ន្ធនឹងមិនពិចារណាលើការប្រើប្រា ស់អត្ថប្រយោជន៍ដែលមិនមែនជាសាច់ប្រាក់របស់កូនអ្នក (ដូចជាការធានារ៉ាប់រងសុខភាព ឬប័ណ្ណមួបអាហារ) នៅក្នុងពាក្យសុំណើរ
សុំផ្ទាល់ខ្លួនរបស់អ្នកសម្រាប់ប័ណ្ណពណ៌បៃតង ឬចូលទៅក្នុងសហរដ្ឋអាមេរិក។
ប៉ុន្តែចំនួនកូនដែលអ្នកមានរួមទាំងកូនដែលមានស
ញ្ញាតិផងអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការសម្រេចថាបុគ្គលណាជាបុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយ ប្រយោជន៍សាធារណ:ឱ្យ ពីព្រោះវាមានផលប៉ះពាល់ដល់ទំហំគ្រួសារ។
<u>យើងសូមណែនាំឱ្យអ្នកនិយាយជាមួយមេធាវីអន្តោប្រវេសន៍អំពីករណីរបស់អ្នក។</u>

7.
តើអត្ថប្រយោជន៍សាធារណ:ដែលរដ្ឋាភិបាលផ្តល់ឱ្យត្រូវបានអនុវត្តចំពោះជនអន្តោប្រវេសន៍ទាំងអស់ ឬទេ?

ការធ្វើតេស្តសម្រាប់បុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណ:អោយគឺមើលទៅមុខដែលមានន័យ ថាការធ្វើតេស្តនេះមិនអាស្រ័យលើអ្វីដែលបានកើតឡើងក្នុងអតីតកាលតែមួយមុខទេ។
ប្រសិនបើអ្នកបានទទួលអត្ថប្រយោជន៍ពីមុនប៉ុន្តែស្ថានភាពរបស់
អ្នកបានផ្លាស់ប្តូរអ្នកប្រហែលជាអាចបង្ហាញថាអ្នកនឹងមិនត្រូវការសេវាកម្មទាំងនោះនៅពេលនេះឬពេលអនាគត (ឧទាហរណ៍ប្រសិនបើអ្នកមានការងារថ្មី)។

ប្រសិនបើអ្នកមានសំណួរអំពីស្ថានភាពជាក់ស្តែងរបស់អ្នក ឬការប្រើប្រាស់អត្ថប្រយោជន៍ អ្នកគួរតែនិយាយជាមួយមេធាវីអន្តោប្រវេសន៍ ឬអ្នកតំណាងដែលទទួលស្គាល់ដោយ DOJ។

8.
តើអត្ថប្រយោជន៍សាធារណៈដែលរដ្ឋាភិបាលផ្តល់អោយត្រូវបានអនុវត្តចំពោះជនអន្តោប្រវេសន៍ទាំងអស់ឬទេ?
ទេ!ការធ្វើតេស្តសម្រាប់បុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈអោយគឺមិនត្រូវបានប្រើសម្រាប់បុគ្គលដែលកាន់ ប័ណ្ណបៃតងនៅក្នុងពាក្យស្នើសុំធ្វើជាពលរដ្ឋអាមេរិកនោះទេ។

ដូចគ្នានេះផងដែរជនអន្តោប្រវេសន៍មនុស្សធម៌មួយចំនួនត្រូវបានលើកលែងពីការធ្វើតេស្តសម្រាប់បុគ្គលដែលរដ្ឋាភិបាលត្រូវចំណាយប្រយោជន៍សាធារណៈឱ្យឬអាចមានសិទ្ធទទួលបានប្រយោជន៍សាធារណៈដែលរដ្ឋាភិបាលផ្តល់ឱ្យ។ នៅរួមបញ្ចូល::

- ជនភៀសខ្លួន
- អ្នកសុំជ្រកកោន (ជនអន្តោប្រវេសន៍ដែលកំពុងស្នើសុំឬត្រូវបានផ្តល់សិទ្ធិជ្រកកោន)
- បុគ្គលដែលដាក់ពាក្យសុំប័ណ្ណបៃតងនៅក្រោមច្បាប់ Violence Against Women Act (VAWA អំពើហិង្សាលើស្ត្រី)
- បុគ្គលដែលមានឬកំពុងស្នើសុំ U ទិដ្ឋាការឬ T ទិដ្ឋាការ
- កុមារដែលកំពុងស្វែងរក Special Immigrant Juvenile Status (ស្ថានភាពអនីតិជនពិសេសអន្តោប្រវេសន៍)

ប្រសិនបើអ្នកស្ថិតនៅក្រោមប្រភេទទាំងនេះអ្នកអាចប្រើអត្ថប្រយោជន៍ណាមួយដែលអ្នកមានសិទ្ធិ។ នេះរួមបញ្ចូលទាំងជំនួយថវិការថែទាំសុខភាពកម្មវិធីម្ហូបអាហារនិងកម្មវិធីមិនមែនសាច់ប្រាក់ផ្សេងទៀត។

9.
ចុះបើខ្ញុំមានប័ណ្ណបៃតងហើយខ្ញុំកំពុងទទួលបានអត្ថប្រយោជន៍?
នៅក្រោមច្បាប់ដែលបានស្នើ អ្នកមិនអាចបាត់បង់ប័ណ្ណពណ៌បៃតងរបស់អ្នកដោយគ្រាន់តែអ្នក កូនរបស់អ្នក ឬសមាជិកគ្រួសារ ១ដទៃទៀតប្រើប្រាស់អត្ថប្រយោជន៍ដោយស្របច្បាប់នោះទេ។ ហើយអ្នកមិនអាចត្រូវបានបដិសេធមិនអោយចូលសញ្ជាតិអាមេរិកចំពោះការទទួលបានអត្ថប្រយោជន៍ស្របច្បាប់នោះទេ។

10.
ចុះបើខ្ញុំជាពលរដ្ឋអាមេរិកហើយកំពុងទទួលបានអត្ថប្រយោជន៍?
អត្ថប្រយោជន៍សាធារណៈដែលរដ្ឋាភិបាលផ្តល់ឱ្យមិនបានកំណត់ចំពោះពលរដ្ឋអាមេរិកនោះទេ។ ប្រសិនបើអ្នកជាពលរដ្ឋអាមេរិកដែលទទួលបានអត្ថប្រយោជន៍ អ្នកគួរតែបន្តទទួលអត្ថប្រយោជន៍ដែលអ្នកមានសិទ្ធិទទួលបាន។

11.
តើខ្ញុំគួតែបញ្ឈប់អត្ថប្រយោជន៍ដែលពួកយើងកំពុងទទួលបានពេលនេះទេ?
ទេ! ប្រសិនបើអ្នក ឬក្រុមគ្រួសាររបស់អ្នកកំពុងទទួលបានអត្ថប្រយោជន៍ដើម្បីទៅជួបគ្រូពេទ្យ បង់ថ្លៃម្ហូបអាហារ ឬបង់ថ្លៃឈ្នួលផ្ទះ
អ្នកមិនចាំបាច់បញ្ឈប់ការទទួលអត្ថប្រយោជន៍របស់អ្នកដោយផ្អែកលើច្បាប់ដែលបានស្នើនោះទេ។ ច្បាប់ដែលស្នើគឺនៅមិនទាន់ សំរេចជាធរមាននៅឡើយទេ។
វានឹងមិនមានប្រសិទ្ធភាពសំរាប់ពេលជាច្រើនខែទៀត។ ច្បាប់ដែលបានស្នើឡើងនេះនឹងមិនត្រូវបានអនុវត្តលើអ្វីដែលមានប្រសិទ្ធភាពរួចហើយនោះទេដែលមានន័យថារដ្ឋាភិបាលនឹងមិនចាត់ទុកការប្រើប្រាស់អត្ថប្រយោជន៍ថ្មីបន្ថែមរបស់បុគ្គលមុនពេលដែលច្បាប់នេះមានប្រសិទ្ធភាពនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់អត្ថប្រយោជន៍ដែលជាផ្នែកមួ យនៃអត្ថប្រយោជន៍សាធារណៈដែលរដ្ឋាភិបាលផ្តល់អោយរួចហើយដូចជា TANF, SSI និងស្ថាប័នរយៈពេលវែង រដ្ឋាភិបាលនឹង

ពិចារណាការប្រើប្រាស់មុនពេលដែលច្បាប់មានប្រសិទ្ធិភាព។សូមនិយាយទៅកាន់មេធាវីអន្តោប្រវេសន៍ចំពោះសំណួរជាក់លាក់ណាមួយ។

12.
ចុះបើខ្ញុំទទួលបានអត្ថប្រយោជន៍ដែលមិនបានចុះបញ្ជី?

មានតែអត្ថប្រយោជន៍ដែលបានចុះបញ្ជីក្នុងច្បាប់ដែលស្នើឡើងតែប៉ុណ្ណោះ (សូមមើលសំណួរទី 4) ដែលអាចនឹងត្រូវពិចារណា។ អត្ថប្រយោជន៍ដែលមិនបានចុះបញ្ជីដូចជាការអប់រំ ការអភិវឌ្ឍចំពោះកុមារ អាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ និងកាត់បន្ថយថ្លៃ និងកម្មវិធីបណ្តុះបណ្តាលការងារ និងការងារមិនមែនជាផ្នែកមួយនៃការធ្វើតេស្តដើម្បីកំណត់ថាបុគ្គលណាមាន សិទ្ធិទទួលបានអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់ឱ្យនោះទេ។

កម្មវិធីក្នុងតំបន់ផ្សេងៗនៅក្នុងក្រុង Utility Discount Program (កម្មវិធីបញ្ចុះតម្លៃឧបករណ៍ប្រើប្រាស់) និងក Seattle Preschool Program (កម្មវិធីបញ្ចុះតម្លៃឧបករណ៍ប្រើប្រាស់) នឹងមិនត្រូវបានពិចារណាទេ។

ចូលទីនេះដើម្បីមើលកម្មវិធីជាច្រើននៃទីក្រុង ស៊ីថល ដែលអ្នកអាចមានសិទ្ធិទទួលបានដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក: www.seattle.gov/affordable។

13.
តើខ្ញុំអាចត្រូវបានដកចេញពីបុគ្គលដែលត្រូវទទួលបានអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់ឱ្យដែរទេ?

នៅក្រោមច្បាប់បច្ចុប្បន្ន ក្នុងកាលៈទេសៈដ៏កម្រដែលបុគ្គលម្នាក់ដែលបានក្លាយបុគ្គលដែលត្រូវទទួលបានអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់ឱ្យត្រូវបានដកចេញ។ ច្បាប់ទាំងនោះភ្ជាប់ជាមួយ ស្នើរតែមិនដែលបានអនុវត្ត។ ការស្នើសុំថ្មីនេះមិនបានមានន័យថា ឬបន្ថែមលក្ខខណ្ឌសំរាប់ការដកចេញ ឬជម្រុសចេញនោះទេ។

14.
តើអ្វីជាការផ្លាស់ប្តូរដែលបានស្នើផ្សេងទៀតរបស់ ក្រាម ក្នុងសំណើថ្មីនេះ?

ក្រៅពីលក្ខខណ្ឌថ្មីដែលបានចុះបញ្ជីក្នុងសំណួរទី 4 សំណើថ្មីនេះក៏នឹង:

អនុវត្តចំពោះកេស្តស្រដៀងគ្នានឹង:

1) ស្នើសុំពន្យារទិដ្ឋាការមិនមែនអន្តោប្រវេសន៍ (ឧទាហរណ៍ស្នាក់នៅសហរដ្ឋអាមេរិកបានយូរជាមួយនឹងទិដ្ឋាការទេសចរណ៍របស់អ្នក) និង
2) ស្នើសុំផ្លាស់ប្តូរស្ថានភាពមិនមែនអន្តោប្រវេសន៍របស់អ្នក (ឧទាហរណ៍ការផ្លាស់ប្តូរពីទិដ្ឋាការសិស្សទៅទិដ្ឋាការការងារ) ។

ធ្វើការបញ្ជាក់នៅពេលដែលជនអន្តោប្រវេសន៍ស្វែងរកការកែតម្រូវស្ថានភាពដែលនឹងត្រូវបានអនុញ្ញាតិឱ្យដាក់ប្រកាសចំណង។ ក្រោមច្បាប់ដែលបានស្នើឡើង ជនអន្តោប្រវេសន៍ដែលត្រូវបានចាត់ទុកថាមិនអាចទទួលបានអត្ថប្រយោជ ន៍សាធារណៈពីរដ្ឋាភិបាលអាចនឹងត្រូវប្រកាសអោយបង់ប្រាក់យ៉ាងហោចណាស់ $10,000។

15.
ចុះចំពោះកុមារដែលទទួលបានការធានារ៉ាប់រងសុខភាព?

កុមារដែលកំពុងស្នើសុំប័ណ្ណបៃតងអាចជាកម្មវត្ថុនៃច្បាប់ថ្មីដែលបានស្នើឡើង។ ហើយប្រសិនបើពួកគេទទួលបាន Medicaid, នេះអាចត្រូវបានគេកំណត់នៅក្នុងការធ្វើតេស្តកំណត់បុគ្គលដែលត្រូវទទួលបានអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់អោយរួមជាមួយអាយុ ប្រាក់ចំណូលបស់ពួកគេនិងកត្តាផ្សេងៗទៀត។ រដ្ឋាភិបាលបានស្នើសុំបញ្ចូលថាតើត្រូវដាក់បញ្ចូល Children's Health Insurance Program (CHIP, កម្មវិធីធានារ៉ាប់រងសុខភាពកុមារ) នៅក្នុងបំលាស់ប្តូរច្បាប់ចុងក្រោយនេះដែរទេ ប៉ុន្តែកម្មវិធីនេះមិនត្រូវបានបញ្ចូលក្នុង អត្ថបទបទបញ្ជាបច្ចុប្បន្ននេះទេ។ កុមារដែលជាពលរដ្ឋអាមេរិកមិនត្រូវបានកំណត់ឱ្យធ្វើតេស្តកំណត់បុគ្គលដែលត្រូវទទួលបា នអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់ឱ្យនោះទេ។

16.
តើសំណើថ្មីនេះនឹងប៉ះពាល់ដល់បុគ្គលដែលមានពិការភាពយ៉ាងដូចម្តេច?
ក្រោមច្បាប់ដែលបានស្នើឡើងសុខភាពរបស់មនុស្សម្នាក់គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលរដ្ឋាភិបាលនឹងពិចារណាក្នុងការកំណត់ថាតើបុគ្គលម្នាក់អាចក្លាយជាបន្ទុកសាធារណៈ។
នេះរួមបញ្ចូលទាំងលក្ខខណ្ឌសុខភាពរាងកាយ
ឬផ្លូវចិត្តដែលអាចដាក់កម្រិតសមត្ថភាពរបស់មនុស្សក្នុងការធ្វើការ រៀនសូត្រ ឬថែរក្សាខ្លួនឯង។

ទោះជាយ៉ាងណាក៏ដោយច្បាប់ដែលបានស្នើក៏បានចែងថាការផ្លាស់ប្តូរនឹងមិនត្រូវបានអនុវត្តចំពោះអត្ថប្រយោជន៍ (ក្រៅពីជំនួយផ្នែកសាច់ប្រាក់ ឬការថែទាំរយៈពេលវែង)
ដែលអ្នកបានទទួលមុនពេលច្បាប់នេះត្រូវបានសំរេចជាធរមាន។

<u>យើងសូមណែនាំឱ្យអ្នកនិយាយជាមួយមេធាវីអន្តោប្រវេសន៍អំពីករណីរបស់អ្នក។</u>

17.
ខ្ញុំមានបណ្ណ៍បៃតងរបស់ខ្ញុំហើយខ្ញុំត្រូវបន្តវាក្នុងពេលនាប់ៗនេះ។
តើរដ្ឋាភិបាលអាចបដិសេធពាក្យសុំឡើងវិញរបស់ ខ្ញុំទេពីព្រោះខ្ញុំទទួលបានជំនួយ Medicaid ស្បៀងអាហារនិង/ឬជំនួយលំនៅដ្ឋាន?
ទេ!គេស្គុកំណត់បុគ្គលដែលត្រូវទទួលបានអត្ថប្រយោជន៍ដែលរដ្ឋាភិបាលផ្តល់អោយមិនត្រូវបានអនុវត្តទេនៅពេលអ្នកបន្តកាតពណ៌បៃតងនោះទេ។
ពាក្យស្នើសុំបន្ទុមិនអាចត្រូវបានបដិសេធដោយសារតែអ្នក
ប្រើប្រាស់កម្មវិធីដែលអ្នកមានសិទ្ធិទទួលបានឡើយ។

18.
តើពលរដ្ឋអាមេរិកអាចបាត់បង់សញ្ជាតិរបស់ពួកគេទេ ប្រសិនបើពួកគេប្រើកម្មវិធីដូចជា Medicaid ឬ SNAP/តែមអាហារ?
ទេ!
ប្រជាពលរដ្ឋអាមេរិកមិនអាចបាត់បង់សញ្ជាតិរបស់ពួកគេដោយផ្អែកលើការប្រើផលប្រយោជន៍សាធារណៈស្របច្បាប់របស់ពួកគេនោះទេ។

19.
នៅពេលណាដែលសំណើថ្មីអាចត្រូវបានអនុម័តនិងចាប់ផ្តើម?
ពួកយើងមិនដឹងប្រាកដនោះទេ។
រដ្ឋាភិបាលសហព័ន្ធត្រូវតែអនុវត្តតាមដំណើរការដ៏វែងឆ្ងាយមួយមុនពេលច្បាប់ដែលបានស្នើឡើងក្លាយជាធរមាន និងសកម្ម រួមទាំងរយៈពេល 60 ថ្ងៃនៃមតិយោបល់ជាសាធារណៈ។ មុនពេលគោលការណ៍ក្លាយជាធរមាន
រដ្ឋាភិបាលត្រូវតែពិនិត្យ និងឆ្លើយតបទៅកាន់មតិយោបល់ដែលបានទទួល។

20.
អ្នកអាចប្រាប់រដ្ឋាភិបាលសហព័ន្ធពីអ្វីដែលអ្នកគិតអំពីគោលនយោបាយនេះ:
ច្បាប់ដែលបានស្នើឡើងនេះនៅមិនទាន់បានសំរេចនៅឡើយទេ។ អ្នកមានពេលរហូតដល់ថ្ងៃច័ន្ទទី 10 ខែធ្នូដើម្បីចែករំលែកគំនិតរបស់អ្នកអំពីសំណើថ្មីដោយដាក់បញ្ចូលមតិយោបល់របស់អ្នកជា "មតិយោបល់សាធារណៈ" ទៅកន្លែងបោះពុម្ពផ្សាយដែលហៅថា "Federal Register (ការចុះឈ្មោះសហព័ន្ធ)។"
អ្នកអាចដាក់បញ្ចូលមតិយោបល់របស់ អ្នកជាភាសាអង់គ្លេសតែប៉ុណ្ណោះ។
អ្នកមិនចាំបាច់ទាល់តែជាពលរដ្ឋអាមេរិកទើបអាចមានសិទ្ធដាក់បញ្ចូលមតិយោបល់បាននោះទេ។
ច្បាប់ដែលបានស្នើឡើងនេះនឹងមិនអាចសំរេចបានទេរហូតទាល់តែរដ្ឋាភិបាលបានពិចារណាលើគ្រប់មតិទាំងអស់។

ដើម្បីដាក់បញ្ចូលមតិយោបល់របស់អ្នកផ្ទាល់ សូមចុចនៅទីនេះ៖ www.citiesforaction.us/publiccharge។